# សិលាចារឹកភូមិប្រឡាយ

សិលាចារឹកនេះ រកឃើញដោយលោក រឿង រ៉ាត់ ជាអ្នកស្រុករស់នៅភូមិប្រឡាយ ឃុំបឹងខ្យាង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល មានកម្ពស់ប្រវែង ៧៣ស.ម. ទទឹង ៤៧ស.ម. និងកម្រាស់ ៩ស.ម. ហើយបានយកមករក្សាទុកនៅមន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តកាលពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៨។ សិលាចារឹកនេះ ចារឹកនៅលើថ្មថ្ងើមអណ្ដើក (ថ្មស៊ីស) និងរូបខ្ញុំបាទផ្ទាល់បានទទួលរូបសំណៅផ្តិតពីលោក រិន ពេជ្រដ្ឋ (មន្ត្រីរាជការនៃមន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តកណ្ដាល)។

សិលាចារឹកនេះមានលក្ខណៈមិនពេញលេញនោះទេ ដោយផ្នែកខាងលើរបស់សិលាចារឹកបានបាត់បង់ទិន្នន័យមួយផ្នែកធំទៅហើយ។ យើងអាចនិយាយបានថា សិលាចារឹកនេះចែកចេញជាបីផ្នែក គឺផ្នែកខាងលើចារឹកជាភាសាខ្មែរបុរាណ ផ្នែកកណ្ដាលចារឹកជាភាសាសំស្ក្រឹត និងផ្នែកខាងក្រោមចារឹកជាភាសាខ្មែរបុរាណវិញ។ ផ្នែកខាងលើយើងអាចអានបានតែពាក្យមួយចំនួនប៉ុណ្ណោះ ដែលរៀបរាប់អំពីតង្វាយដល់ទេវស្ថានណាមួយ។ រីឯផ្នែកទី២ ចារឹកជាភាសាសំស្ក្រឹត មានចំនួន ២បន្ទាត់ ស្មើនឹង ១ស្លោក ដែលជាប្រភេទកំណាព្យមានចំនួន ៨ព្យាង្គ ហៅថា អនុស្ដុភ ឬច្រើនហៅថា ស្លោក ជាឆន្ទមួយប្រភេទ មាន៤បាទ ក្នុង១បាទមាន៨ព្យាង្គ។ កំណាព្យប្រភេទនេះខ្មែរបុរាណនិយមណាស់ ព្រោះងាយស្រួលក្នុងការតាក់តែង និងមានសំលេងសូត្រពីរោះរណ្ដំ។ ស្លោកនេះរៀបរាប់អំពី "ដរាបណាឱ្យតែព្រះចន្ទ្រ ព្រះអាទិត្យ ស្ថិតនៅព្រះធម៌នៅមានក្នុងលោកនេះ អាជ្ញាឬរាជសាសន៍ ក៏រមែងស្ថិតនៅជាដរាបផងដែរ"។ ផ្នែកខាងក្រោមជាភាសាខ្មែរ រៀបរាប់អំពីតង្វាយរបស់ព្រាហ្មណ៍ម្នាក់ឈ្មោះ ប្អញតាងក្វើង ដែលតង្វាយមានដូចជា ដីស្រែ ដើមស្លា ដើមដូង។

## អត្ថបទពាក្យចារឹក

១. ត្មុរ៑ ៤០-៣ [ដី គុ ដេះ ពោះ] ......................

២. យាវត្តិឞ្ឋតិកៃលេន្ទ្រ ក្វន្ទ្រាកោ៌ចរតោជិវិ

៣. យាវទ្ធម្ម៌ស្ថិតោលោកេ យាវជ្ជាត្រតិឞ្ឋតិ។

៤. ស្រេ វ្រះ សរវ ៦ ស្វាត្នេំ ២០-៩ តោដី ត្នេំ ២០-៣

៥. ដី គុ ដេះ គុ ពោះ អំណោយិ ប្អញ តាដី វ្វដី ត វ្រះ //

អត្ថបទដោយ៖ កំ វណ្ណារ៉ា

## សេចក្ដីប្រែសម្រួល

១. គោ ចំនួន ៤៣ ក្បាល នេះគឺជាតង្វាយ ......

(បន្ទាត់ទី២-៣) ដរាបណាកៃលេន្ទ្រ (ស្ដេចភ្នំ) ស្ថិតនៅ, ដរាបណាឱ្យតែព្រះចន្ទ ព្រះអាទិត្យ នៅត្រាច់គោចរ ដរាបណាឱ្យតែព្រះធម៌ (ច្បាប់អាជ្ញា) ស្ថិតស្ថិរក្នុងលោកនេះ ដរាបនោះ អាជ្ញា (ព្រះរាជអាជ្ញា) រមែងស្ថិតនៅមាននៅក្នុងទីនេះជាដរាបតទៅ។

(បន្ទាត់ទី៤-៥) ស្រែព្រះមានចំនួន ៦ សរេ ដើមស្វាចំនួន២៩ដើម ដើមដូងចំនួន ២៣ដើម ទាំងនេះគឺជាអំណោយរបស់ព្រះតេជគុណ ប្អូញ តាង ភ្ញើង ថ្វាយដល់ព្រះ (ទេវស្ថាន)។

### ពន្យល់វាក្យស័ព្ទ

- ត្នរ៑ = គោ
- ស្រែ វ្រះ = ស្រែព្រះ
- សរេ = ខ្នាតវាស់ដីស្រែ (សរេ ឬ សង្រែ)
- ស្វាត្នំ = ដើមស្វា
- តោជីត្នំ = ដើមដូង
- យាវតិ = ដរាបណា
- តិឞ្ឋតិ = តាំងនៅ, ស្ថិតនៅ
- កៃលេន្ទ្រ (កៃល + ឥន្ទ្រ) = ស្ដេចភ្នំ, ទេវស្ថាន
- ចន្ទ្រាក៌ោ (ចន្ទ្រ + អក៌ះ) = ព្រះចន្ទ្រ និងព្រះអាទិត្យ
- ចរតោ = នៅគោចរ, នៅតែមាន
- ចរតោជិរី = នៅតែគោចរ ឬនៅតែធ្វើដំណើរ
- ធម៌្មស្ថិតោលោកេ (ធម៌្ម + ស្ថិត + លោកេ) = ព្រះធម៌ស្ថិតនៅមានក្នុងលោក
- អាជ្ញា = បទបញ្ជា, សេចក្ដីប្រកាស, សារាចរ
- អត្រ = ក្នុងទីនេះ

អត្ថបទដោយ៖ កំ វណ្ណារ៉ា



សំណៅផ្តិតសិលាចារឹកភូមិប្រឡាយ (ដោយ៖ រិន ពេជ្ររដ្ឋ)

អត្ថបទដោយ៖ កំ វណ្ណាវ៉ា